អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# កិច្ចប្រជុំពេញអង្គមន្ត្រីតុលាការលើកទី៤

(ថ្ងៃទី០១-០៥ ខែកញ្ញា ឆ្នាំ២០០៨)

កិច្ចប្រជុំពេញអង្គមន្ត្រីតុលាការលើកទី៤ នៃ អ.វ.ត.ក នឹងត្រូវប្រារព្ធធ្វើឡើងនៅសណ្ឋាគារ Raffles Hotel Le Royal ក្នុងរាជធានីភ្នំពេញ ពីថ្ងៃទី០១ ដល់ទី០៥ ខែកញ្ញា ឆ្នាំ២០០៨។ កិច្ចប្រជុំពេញអង្គនឹងចាប់ផ្តើមនៅថ្ងៃច័ន្ទទី០១ ខែកញ្ញា ដោយមានកិច្ចប្រជុំត្រៀមរៀបចំរយៈពេលកន្លះថ្ងៃ។ ពិធីបើកកិច្ចប្រជុំផ្លូវការនឹងធ្វើឡើងនៅថ្ងៃដដែល វេលាម៉ោង ១៣:៣០។

កិច្ចប្រជុំពេញអង្គគឺជាការប្រជុំបិទទ្វារ តែសារព័ត៌មានត្រូវបានអញ្ជើញឱ្យចូលរួមពិធីបើកកិច្ចប្រជុំនៅថ្ងៃច័ន្ទទី០១ ខែកញ្ញា ឆ្នាំ២០០៨ ចាប់ផ្តើមពីម៉ោង ១៣:៣០។ ពួកគេនឹងទទួលបានឱកាសជាផ្លូវការក្នុងការថតរូបភាព។ នៅពេលបញ្ចប់កិច្ចប្រជុំពេញអង្គ ការិយាល័យកិច្ចការសាធារណៈរបស់ អ.វ.ត.ក នឹងចេញសេចក្តីថ្លែងការណ៍សង្ខេប ផ្តល់ជូនសារព័ត៌មានទាំងអស់ដែលមានចំណាប់អារម្មណ៍។

យើងស្នើសុំឱ្យតំណាងសារព័ត៌មានទាំងអស់ដែលមានចំណាប់អារម្មណ៍ក្នុងការចូលរួមថតរូបភាព សូមមេត្តាទាក់មន្ត្រីអ្នកនាំពាក្យ អ.វ.ត.ក លោក រាជ សម្បត្តិ តាមរយៈទូរស័ព្ទលេខ ០១២ ៤៨៨ ១៥៦ ឬ អ៊ីមែល៖ reach.sambath@eccc.gov.kh។

សូមកត់សម្គាល់ថា លោកអ្នកត្រូវមានឯកសារកំណត់អត្តសញ្ញាណមានសុពលភាព ដើម្បីចូលរួមព្រឹត្តិការណ៍សារព័ត៌មានទាំងអស់នៅ អ.វ.ត.ក។